ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៚ ❖ ៚

ក្រសួងអប់រំយុវជន និង កីឡា
លេខ : ៤០៥ អយក.ប្រក

# ប្រកាស
## ស្តីពីការបើកសាលាបឋមសិក្សា ពោធិតូច

### រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស . រកត - ១១៩៨ - ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ២១អនក្រ.បក ចុះថ្ងៃទី២៣ ខែ មិនា ឆ្នាំ ៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិត ៩០១ អយក.តបម ចុះថ្ងៃទី ២៤ ខែ ១២ ឆ្នាំ ២០០១ របស់មន្ទីរអប់រំ យុវជន និង កីឡាខេត្ត តាកែវ
- តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

### ស ំ រ េ ច

**ប្រការ១** :-បើកសាលាបឋមសិក្សា ពោធិតូច ដែលមានទីតាំងស្ថិតនៅភូមិ ព្រៃកតាចង់ ឃុំ ពោធិ៍ចាក ស្រុក ព្រៃកប្បាស ខេត្ត តាកែវ ជាសាលាបឋមសិក្សាពេញលក្ខណៈ ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២** :-សាលាបឋមសិក្សា ពោធិតូច ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**ប្រការ៣** :-បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤** :-នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត តាកែវ ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក ព្រៃកប្បាស នាយកសាលាបឋមសិក្សា ពោធិតូច មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ .ថ្ងៃទី២៨ ខែឧសភា ឆ្នាំ ២០០២
ជ-រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា
រដ្ឋលេខាធិការ

អ៊ឹម_សិទ្ធី

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាបជាពត៌មាន"
- សាលាខេត្ត តាកែវ "ជូនជ្រាបជាពត៌មាន"
- ដូចប្រការ ៤
- កាលប្បវត្តិ
- ឯកសារ នា.បម